មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌
## ការពន្យល់ប្រាប់សិទ្ធិ

www.cchrcambodia.org

លេខ១០ - ខែ កក្កដា ២០២០

***មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា៖*** *"ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទ ឲ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់មកលើខ្លួន។"*

***មាត្រា១៤ (៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖***
*"ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិត្រូវទទួលបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ។"*

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានធ្វើការសង្កេតការណ៍សវនាការចាប់តាំងពីឆ្នាំ២០០៩ ដើម្បីតាមដានសវនាការព្រហ្មទណ្ឌក្នុងតុលាការ និងវាយតម្លៃអំពីការអនុវត្តបទដ្ឋានជាតិ និងអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌។ ចាប់តាំងពីខែមីនា ឆ្នាំ២០១៣ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក បានសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញ។ ព្រឹត្តិបត្រព័ត៌មាននេះគឺជាការចេញផ្សាយជាស៊េរីដែលវិភាគលើរបកគំហើញពីការសង្កេតសវនាការរបស់ ម.ស.ម.ក។ ព្រឹត្តិបត្រព័ត៌មាននេះផ្តោតលើកាតព្វកិច្ចរបស់ចៅក្រមជំនុំជម្រះក្នុងការប្រាប់ជនជាប់ចោទអំពីបទចោទប្រកាន់មកលើខ្លួន និងភារកិច្ចរបស់ចៅក្រមក្នុងការពន្យល់អំពីសិទ្ធិមានមេធាវី ឬការពារខ្លួនដោយផ្ទាល់ខ្លួនឯង ព្រមទាំងសិទ្ធិនៅស្ងៀម ដើម្បីរួចផុតពីការឆ្លើយដាក់បន្ទុកលើខ្លួនឯង។ រាល់ទិន្នន័យដែលប្រមូលបានគឺមានផ្សព្វផ្សាយជាសាធារណៈក្នុងប្រព័ន្ធទិន្នន័យការសង្កេតការណ៍សវនាការរបស់យើង។

## ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ

បុគ្គលដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ មានសិទ្ធិត្រូវដឹងអំពីប្រភេទ និងមូលហេតុនៃអំពើ ដែលបានចោទប្រកាន់មកលើខ្លួនឲ្យបានឆាប់បំផុត។ ចៅក្រមមានកាតព្វកិច្ចពន្យល់ឲ្យបានសព្វគ្រប់ និងធានាថាជនជាប់ចោទយល់ពីបទចោទប្រកាន់ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន។ ប្រសិនបើគ្មានព័ត៌មានចាំបាច់ទាំងនេះទេ ជនជាប់ចោទមិនអាចរៀបចំការពារក្តី ឬដើម្បីផ្តល់ព័ត៌មានលម្អិតគ្រប់គ្រាន់ដល់មេធាវីបានទេ ក្នុងករណីដែលជនជាប់ចោទនោះត្រូវបានតំណាងដោយមេធាវី។ បន្ថែមលើនេះ ចៅក្រមត្រូវតែប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់ខ្លួនក្នុងការស្វែងរកមេធាវី ឬការពារខ្លួនដោយផ្ទាល់ខ្លួនឯង។ ចៅក្រមត្រូវធានាថែមទៀតថាជនជាប់ចោទដឹងពីសិទ្ធិនៅស្ងៀម និងសិទ្ធិមិនឆ្លើយសារភាពពីពិរុទ្ធភាពរបស់ខ្លួន។ ចៅក្រមត្រូវប្រាប់សិទ្ធិទាំងនេះដល់ជនជាប់ចោទនៅពេលសវនាការជំនុំជម្រះឲ្យបានឆាប់បំផុត។

សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការទទួលបានការការពារខ្លួន មានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") រីឯមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា "អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។" យោងតាមមាត្រា ១២៩ ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ មាត្រា ៣០០ និងមាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") ចែងថា ជនជាប់ចោទត្រូវអមដោយមេធាវីដែលខ្លួនជ្រើសរើស។ មាត្រា ៣២៥ នៃក្រមនិតីវិធីព្រហ្មទណ្ឌចែងថា ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទ ឲ្យដឹងអំពីអំពើដែលគេចោទប្រកាន់លើខ្លួន។ ហើយ មាត្រា ៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ចែងពីការពន្លាតនូវវិធាន ដែលអនុវត្តចំពោះសាលាដំបូងដល់សាលាឧទ្ធរណ៍ផងដែរ។ មាត្រា ៥១ នៃច្បាប់ស្តីពីយុត្តិធម៌ អនីតិជនចែងថា"ពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសា ដែលអនីតិជនអាចយល់បានអំពីសិទ្ធិដូចខាងក្រោម៖ សិទ្ធិដែលទាក់ទងនឹងដំណាក់កាលជំនុំជម្រះដូចមានចែងក្នុងមាត្រា៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ"។

បន្ថែមលើនេះ មាត្រា ១៤(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ដែលកម្ពុជាជារដ្ឋភាគី និងត្រូវបានបញ្ចូលទៅក្នុងច្បាប់ជាតិតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថា "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន បុគ្គលគ្រប់រូបមានសិទ្ធិត្រូវបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ។" កថាខណ្ឌ (៣)(ឃ) នៃមាត្រានេះចែងបន្ថែមថា បុគ្គលគ្រប់រូបត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ទេនោះ។ ជាចុងក្រោយកថាខណ្ឌ (៣)(ឆ) នៃមាត្រាដដែល ការពារបុគ្គលពីការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង ដែលប្រឆាំងនឹងការប្រើកម្លាំងបង្ខំ ឬការគំរាម ដើម្បីទទួលបានការសារភាពអំពីពិរុទ្ធពីជនណាមួយ។

អនុលោមតាមមាត្រា ២ នៃ ក.អ.ស.ព.ន កម្ពុជាត្រូវគោរព និងធានាឲ្យមានការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលមានចែងនៅក្នុងមាត្រា ១៤ និងចាត់វិធានការចាំបាច់ដើម្បីអនុម័តច្បាប់ ឬវិធានការចាំបាច់ដទៃទៀត ដើម្បីផ្តល់នូវប្រសិទ្ធភាពដល់ការអនុវត្តសិទ្ធិទាំងនោះ។

CC BY NC SA

ការអនុវត្តការពន្យល់ប្រាប់សិទ្ធិនៅដំណាក់កាលជំនុំជម្រះគឺចាំបាច់ដើម្បីធានាថាជនជាប់ចោទមានឱកាសក្នុងការរៀបចំការពារក្តីយ៉ាងល្អបំផុតតាមដែលអាចធ្វើបាន ដើម្បីតតាំងនឹងការចោទប្រកាន់ណាមួយមកលើខ្លួន។

**របកគំហើញនៃការសង្កេតការណ៍របស់ ម.ស.ម.ក**

នៅអំឡុងថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ម.ស.ម.ក បានសង្កេតការណ៍សវនាការចំនួន ២៧៣ សំណុំរឿងនៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញ។ នៅគ្រប់សំណុំរឿងទាំងអស់ ម.ស.ម.ក សង្កេតការណ៍មិនត្រឹមតែថាតើចៅក្រមបានប្រាប់អំពីសិទ្ធិរបស់ជនជាប់ចោទដែលត្រូវទទួលបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសង្កេតការណ៍ថាតើចៅក្រមបានពន្យល់ឲ្យបានពេញលេញអំពីសិទ្ធិទាំងនោះដែរ ឬយ៉ាងណា ពោលគឺ សិទ្ធិទទួលបានការពន្យល់ប្រាប់សិទ្ធិ និងការយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ សិទ្ធិមានមេធាវី សិទ្ធិការពារខ្លួនដោយផ្ទាល់ខ្លួនឯង និងសិទ្ធិនៅស្ងៀមដែលចៅក្រមត្រូវប្រាប់ និងពន្យល់នៅពេលសវនាការ។

នៅអំឡុងពេលនៃការសង្កេតការណ៍សវនាការ ម.ស.ម.ក បានរកឃើញថា ភាគច្រើននៃសំណុំរឿង ចៅក្រមបានប្រាប់អំពីការចោទប្រកាន់ដល់ជនជាប់ចោទ និងពន្យល់អំពីប្រភេទនៃការចោទប្រកាន់ដល់ជនជាប់ចោទ ដែលមានសំណុំរឿងចំនួន ១៩៦ (៧២%) ក្នុងចំណោមសំណុំរឿងទាំងអស់។ ទោះយ៉ាងនេះក្តី ក្នុងចំណោមសំណុំរឿងចំនួន ៦៤ (២៣%) ចៅក្រមបានត្រឹមតែពន្យល់ផ្នែកខ្លះអំពីបទចោទប្រកាន់ដល់ជនជាប់ចោទតែប៉ុណ្ណោះ ហើយក្នុងចំណោមសំណុំរឿងចំនួន១៣ (៥%) ចៅក្រមមិនបានប្រាប់អំពីការចោទប្រកាន់ដល់ជនជាប់ចោទឡើយ។ ចំពោះសិទ្ធិមានមេធាវីរបស់ជនជាប់ចោទ ឬការពារខ្លួនដោយផ្ទាល់ខ្លួនឯង មានសំណុំរឿងចំនួន ៣០(១១%) ចៅក្រមបានប្រាប់អំពីសិទ្ធិនេះ។ ចៅក្រមបានពន្យល់អំពីសិទ្ធិនេះត្រឹមតែ ៦ សំណុំរឿង (២%) ប៉ុណ្ណោះ។ ក្នុងចំណោមសំណុំរឿងចំនួន២០ (៧%) ចៅក្រមមិនទាំងបានប្រាប់ និងពន្យល់អំពីសិទ្ធិមានមេធាវី ឬការពារខ្លួនដោយផ្ទាល់ខ្លួនឯងឡើយ។ ក្នុងចំណោមសំណុំរឿងចំនួន១៧៩ (៦៦%) ជនជាប់ចោទមានមេធាវីតំណាង ហេតុដូចនេះ ចៅក្រមមិនចាំបាច់ប្រាប់ពីសិទ្ធិមានមេធាវីឡើយ។ ក្នុងចំណោមសំណុំរឿងចំនួន ៣៨ (១៤%) ជនជាប់ចោទមិនមានវត្តមាននៅក្នុងសវនាការឡើយ។ ទាក់ទងនឹងសិទ្ធិនៅស្ងៀម មានត្រឹមតែសំណុំរឿងចំនួន ៣១ (១១%) ប៉ុណ្ណោះ ដែលចៅក្រមបានទាំងប្រាប់ និងពន្យល់អំពីសិទ្ធិនេះដល់ជនជាប់ចោទ។ ក្នុងចំណោមសំណុំរឿងចំនួន ៦២ (២៣%) ចៅក្រមត្រឹមតែបានប្រាប់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមប៉ុណ្ណោះ ហើយសំណុំរឿងចំនួន ១៤២ (៥២%) ចៅក្រមបានខកខានក្នុងការលើកឡើងអំពីសិទ្ធិនេះ។ ជាចុងក្រោយ ក្នុងចំណោមសំណុំរឿងចំនួន ៣៨ (១៤%) ជនជាប់ចោទមិនមានវត្តមាននៅពេលសវនាការ។

**ការពន្យល់ប្រាប់សិទ្ធិជាតួលេខ**










*មិនពាក់ព័ន្ធ៖ អវត្តមានជនជាប់ចោទនៅពេលសវនាការ

ដោយផ្អែកលើតួលេខខាងលើ បង្ហាញយ៉ាងច្បាស់ថា មានចំនួនសំណុំរឿងតិចនៅឡើយ ដែលចៅក្រមបានប្រាប់ និងពន្យល់ពេញលេញដល់ជនជាប់ចោទអំពីសិទ្ធិរបស់ពួកគេ។ ហេតុដូចនេះ សិទ្ធិរបស់ជនជាប់ចោទមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយទេ ហើយការអនុវត្តរបស់តុលាការបែបនេះគឺមិនបានអនុលោមទៅតាមបទដ្ឋានជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅឡើយ។

cc BY NC SA

**ការវិវឌ្ឍនៃការអនុវត្តចំពោះការពន្យល់ប្រាប់សិទ្ធិ**

ការពន្យល់ប្រាប់សិទ្ធិជនជាប់ចោទដោយចៅក្រមនៅសាលាឧទ្ធរណ៍មានការប្រសើរឡើង បន្ទាប់ពីជំនួបជាមួយក្រុមការងារ ម.ស.ម.ក ជាមួយតុលាការដើម្បីពិភាក្សាអំពីរបាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ឆ្នាំ២០១៩ របស់ ម.ស.ម.ក នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០១៩។ ក្នុងរយៈពេល ៨ ខែបន្ទាប់ពីកិច្ចប្រជុំមក (ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០) ចៅក្រមមិនបានពន្យល់ប្រាប់សិទ្ធិមានមេធាវីដល់ជនជាប់ចោទ មានតែចំនួន ៤% នៃសំណុំរឿងដែលបានសង្កេតការណ៍ (៣ ក្នុងចំណោមសំណុំរឿងចំនួន ៧៥)។ នេះបង្ហាញឱ្យឃើញថាមានភាពប្រសើរឡើងជាងរយៈពេល ៨ ខែមុនកិច្ចប្រជុំ (ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩) ដែលចៅក្រមមិនបានពន្យល់ប្រាប់សិទ្ធិនេះដល់ជនជាប់ចោទ មានចំនួន ៩% (១៧ ក្នុងចំណោមសំណុំរឿងចំនួន ១៩៨) នៃសំណុំរឿងដែលបានសង្កេតការណ៍។ ចំពោះការពន្យល់ប្រាប់សិទ្ធិនៅស្ងៀមវិញ ឃើញថាមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ជាងមុន ដោយសារតែក្នុងរយៈពេល ៨ ខែមុនកិច្ចប្រជុំនេះ ការពន្យល់ប្រាប់សិទ្ធិនេះដល់ជនជាប់ចោទមានត្រឹមតែចំនួន ៥% ប៉ុណ្ណោះ (១០/១៩៨ សំណុំរឿង) នៃសំណុំរឿងដែលបានសង្កេតការណ៍ ហើយបន្ទាប់ពីកិច្ចប្រជុំមក ការពន្យល់ប្រាប់សិទ្ធិនៅស្ងៀមដល់ជនជាប់ចោទ មានចំនួន ២៨% (២១/៧៥ សំណុំរឿង) នៃសំណុំរឿងដែលបានសង្កេតការណ៍។







**អនុសាសន៍៖**

ម.ស.ម.ក អំពាវនាវដល់ចៅក្រមនៃតុលាការនានានៅក្នុងប្រទេសកម្ពុជាឲ្យ៖

- ប្រាប់ និងពន្យល់ពេញលេញដល់ជនជាប់ចោទអំពីការចោទប្រកាន់ប្រឆាំងនឹងពួកគេ។
- ប្រាប់ និងពន្យល់ពេញលេញដល់ជនជាប់ចោទអំពីសិទ្ធិរបស់ពួកគេនៅពេលសវនាការ រួមមាន សិទ្ធិមានមេធាវី សិទ្ធិការពារដោយផ្ទាល់ខ្លួនឯង និងសិទ្ធិនៅស្ងៀមនៅពេលសវនាការ។
- លើកកម្ពស់ការអនុវត្តសិទ្ធិរបស់ជនជាប់ចោទតាមរយៈការជំនុំជម្រះឲ្យបានពេញលេញ និងដោយសេរី។
- អនុវត្តពេញលេញនូវគោលគំនិតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយផ្អែកលើបទដ្ឋានជាតិ និងអន្តរជាតិ និងប្រតិបត្តិតាមការអនុវត្តដ៏ល្អនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។

*ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក លេខមុនៗ អាចរកបានតាមប្រព័ន្ធអ៊ីនធឺណិត (លេខ១ លេខ២ លេខ៣ លេខ៤ លេខ៥ លេខ៦ លេខ៧ លេខ៨ និងលេខ៩)។ លោកអ្នកក៏អាចអានរបាយការណ៍ប្រចាំឆ្នាំ២០១៨ និងរបាយការណ៍ប្រចាំឆ្នាំ២០១៩ របស់យើងស្តីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍" ដែលបានបង្ហាញពីបេកគំហើញសំខាន់ៗពីការសង្កេតការណ៍របស់ខ្លួននៅសាលាឧទ្ធរណ៍ក្នុងរាជធានីភ្នំពេញ។*